# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៥២០
ចុះថ្ងៃទី០៦-០៥-២០២១
សាលដីកា
លេខៈ ៦៥ ក្រ II "ន"
ចុះថ្ងៃទី២១-១០-២០២១

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាម ព្រះរាជក្រមលេខៈ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០-៨-២០០៧ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ ដោយមានសមាសភាព ដូចតទៅៈ

### សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ

| | | |
|---|---|---|
| លោកស្រី | [redacted] | ជាប្រធាន |
| ឯកឧត្តម | [redacted] | ជាចៅក្រមប្រឹក្សា |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |

### តំណាងមហាអយ្យការ

| | | |
|---|---|---|
| លោក | [redacted] | ជាព្រះរាជអាជ្ញា |

### ក្រឡាបញ្ជីសវនាការ

| | | |
|---|---|---|
| លោក | [redacted] | ជាក្រឡាបញ្ជី |

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងក្តីព្រហ្មទណ្ឌលេខ ៥២០ ចុះថ្ងៃទី០៦-០៥-២០២១ ដែលមានៈ

១-ជនជាប់ចោទឈ្មោះ[redacted] រដ្ឋា ហៅ ថា ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតភូមិសែនសុខ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅ ផ្ទះ [redacted]រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ[redacted](រ) នៅរស់ ជាទីតិជន ទោសពីមុនគ្មាន ។ (ប្តឹងឧទ្ធរណ៍)

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥២៣១ "អ" ជ.ឃ.ជ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ ។

២-ជនជាប់ចោទឈ្មោះ[redacted] ហៅ រៈ ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មកររោងចក្រ ទីកន្លែងកំណើតភូមិស្លែ ឃុំគងជ័យ ស្រុកអូររាំងឪ ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់[redacted] ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ [redacted](រ) នៅរស់ ជាទីតិជន ទោសពីមុនគ្មាន ។ (ប្តឹងឧទ្ធរណ៍)

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥២៣២ "អ" ជ.ឃ.ជ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ ។



Scanned with CamScanner

<u>ជាប់ចោទពីបទ</u> លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុស ច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំងរាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងរាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមាន ចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ហ្គិច ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ [redacted] DP១២ ផ្លូវ២២២ ភូមិសែនសុខទី៦ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ជានីតិជន ទោសពីមុនគ្មាន ។ (ប្តឹងឧទ្ធរណ៍)

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៥២៣៩ “ច១” ដ.ឃ.ដ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ។

មានលោក [redacted] ច័ន្ទសុវណ្ណដា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ជនជាប់ចោទឈ្មោះ [redacted] និងជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ។

មានលោក [redacted] សុវណ្ណដារ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ។

៥-ជនជាប់ចោទឈ្មោះ [redacted] ហេង ហៅ ស្រីហេង ភេទ ប្រុស អាយុ ២៦ឆ្នាំ ។

៦-ជនជាប់ចោទឈ្មោះ [redacted] ភា ហៅ ភា ភេទ ប្រុស អាយុ ២២ឆ្នាំ ។

៧-ជនជាប់ចោទឈ្មោះ [redacted] លីប៉ាង ហៅ ប៉ាង ភេទ ប្រុស អាយុ ២២ឆ្នាំ ។

៨-ជនជាប់ចោទឈ្មោះ [redacted] ស្វិត ហៅ ស្វិត ភេទ ប្រុស អាយុ ២៣ឆ្នាំ ។

៩-ជនជាប់ចោទឈ្មោះ [redacted] សុភក្តិ ហៅ ធូ ភេទ ប្រុស អាយុ ២៣ឆ្នាំ ។

១០-ជនជាប់ចោទឈ្មោះ [redacted] ផានិត ហៅ ក្និត ភេទ ប្រុស កើតនៅឆ្នាំ ១៩៩៦ ។

<u>ជាប់ចោទពីបទ</u> លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចមុខសាលាបឋមត្រពាំងរាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងរាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីណាត ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នស្នាក់នៅបន្ទប់ ជួល ផ្លូវបេតុង ភូមិរកា ឃុំឬស្សីស្រុក ស្រុកអង្គស្នួល ខេត្តកណ្តាល ។

## អំពីអង្គហេតុ

កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោង ០៤ និង ០០នាទីទៀបភ្លឺ នៅចំណុចមុខសាលាបឋម



Scanned with CamScanner

សិក្សាត្រពាំងរាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងរាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ មានករណី **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** មួយបានកើតឡើងដែលបង្កដោយជនជាប់ចោទចំនួន ១០នាក់ ឈ្មោះ [redacted] វឌ្ឍា ហៅ ថា ភេទប្រុស អាយុ ១៨ឆ្នាំ, ឈ្មោះ [redacted] រះ ហៅ រះ ភេទប្រុស អាយុ ២៨ឆ្នាំ, ឈ្មោះ [redacted] សុភា ហៅ ភា ភេទប្រុស អាយុ ២២ឆ្នាំ, ឈ្មោះ [redacted] ស្វិត ហៅ ស្វិត ភេទប្រុស អាយុ ២៣ឆ្នាំ, ឈ្មោះ [redacted] លីហ៊ាង ហៅ ហ៊ាង ភេទប្រុស អាយុ ២២ឆ្នាំ, ឈ្មោះ [redacted] សុភក្តិ ហៅ ធូ ភេទប្រុស អាយុ ២៣ឆ្នាំ, ឈ្មោះ [redacted] សុវណ្ណ ហៅ ហ្គិច ភេទប្រុស អាយុ ២២ឆ្នាំ, ឈ្មោះ [redacted] ហេង ហៅ ស្រីហេង ភេទប្រុស អាយុ ២៦ឆ្នាំ, ឈ្មោះ [redacted] ធានិត ហៅ ក្និត ភេទប្រុស អាយុ ២៤ឆ្នាំ និងឈ្មោះ ហុង ភេទប្រុស អាយុប្រហែល ១៧ឆ្នាំ បានធ្វើសកម្មភាពយកកាំបិតផ្គាក់ប្រវែងប្រហែលកន្លះម៉ែត្រ កាប់មកលើជនរងគ្រោះឈ្មោះ [redacted] ស៊ីណាត ភេទប្រុស អាយុ ៣១ឆ្នាំ ។ ដោយនៅមុនពេលកើតហេតុជនរងគ្រោះជិះម៉ូតូម៉ាកសេ១២៥ ស៊េរីឆ្នាំ២០១៧ ពណ៌ខ្មៅ ពាក់ស្លាកលេខ 1W-0477 លេខតួម៉ាស៊ីន ៨៧៧៩៦៣៥ ធ្វើដំណើរតាមបណ្តោយផ្លូវទំនប់កប់ស្រូវ (មហាវិថីវិមានឈ្នះ១) ទិសដៅពីលិចទៅកើត មកដល់ចំណុចកើតហេតុខាងលើ ពេលនោះជនជាប់ចោទឈ្មោះ [redacted] វឌ្ឍា ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ [redacted] រះ ភេទប្រុស អាយុ ២៨ឆ្នាំ និងបក្ខពួកចំនួន ០៨នាក់ទៀត ឈ្មោះខាងលើបាន ឃើញជនរងគ្រោះជិះម៉ូតូតែម្នាក់ឯង ភ្លាមនោះជនជាប់ចោទឈ្មោះ [redacted] ហេង បានបន្ថែមល្បឿនម៉ូតូបើកទៅអែប ទន្ទឹមម៉ូតូរបស់ជនរងគ្រោះ ហើយជនជាប់ចោទឈ្មោះ [redacted] សុភា បានលើក កាំបិតផ្គាក់កាប់មកលើជនរងគ្រោះពី ក្រោយបណ្តាលឱ្យជនរងគ្រោះរបួសស្រាល មានស្នាមជាំ ឆូតចំនួន ០២កន្លែង នៅលើខ្នង រួចជនរងគ្រោះបានដួលម៉ូតូ ហើយក៏ស្ទុះងើបរត់គេចខ្លួន ចំណែកឯបក្ខពួកបានជិះម៉ូតូបិទគូថ ហើយក៏ គេចខ្លួនបាត់តែម្តង ។ បន្ទាប់ពីកើត ហេតុរួចមកជនរងគ្រោះក៏បានដាក់ពាក្យបណ្តឹង នៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃ្មួញ ។ លុះដល់ថ្ងៃទី០១ ខែ មិថុនា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល២២ និង ៣០នាទី សមត្ថកិច្ចបានធ្វើការស្រាវជ្រាវរួច ឃាត់ខ្លួនបានជនជាប់ចោទ ចំនួន ០២នាក់ឈ្មោះ [redacted] រះ ភេទ ប្រុស អាយុ ២៨ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] វឌ្ឍា ភេទប្រុស អាយុ ១៨ឆ្នាំ យកមកអធិការដ្ឋាននគរបាលខណ្ឌសែនសុខ ដើម្បីធ្វើការសាកសួរ និង បានធ្វើតេស្តិ៍ស្វែងរកសារធាតុញៀន ជាលទ្ធផលវិជ្ជមាន ទើបសមត្ថកិច្ចបញ្ជូនជនជាប់ចោទទាំងពីរនាក់ មកតុលាការដើម្បីចាត់ការតាមនីតិវិធី ។

-**បានឃើញ**: សាលក្រមព្រហ្មទណ្ឌលេខ: **១២៧៩ "ច១" ក្រ១០** ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ៖

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ហ្គិច ភេទ ប្រុស អាយុ ២២ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល ០៥ (ប្រាំ)ឆ្នាំ ពីបទ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមុខសាលាបឋម សិក្សាត្រពាំងរាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងរាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រម ព្រហ្មទណ្ឌ តាមមាត្រា ៣៥០ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



Scanned with CamScanner

២-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted]វឌ្ឍា ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ[redacted]រះ ហៅ រះ ភេទ ប្រុស អាយុ ២៨ឆ្នាំ ដាក់ពន្ធនា គារក្នុងម្នាក់ៗ កំណត់រយៈពេល ០៥ (ប្រាំ)ឆ្នាំ ពីបទ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំងវាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងវាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីត្រួតពិនិត្យគ្រឿងញៀន ។

៣-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted] លីហ៊ាង ហៅ ហ៊ាង ភេទប្រុស អាយុ ២២ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បី)ឆ្នាំ ពីបទ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំង វាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងវាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៤-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted]ហេង ហៅ ស្រីហេង ភេទប្រុស អាយុ ២៦ឆ្នាំ,[redacted] សុភា ហៅ ភា ភេទប្រុស អាយុ ២២ឆ្នាំ,[redacted]ស្វិត ហៅ ស្វិត ភេទប្រុស អាយុ ២៣ឆ្នាំ,[redacted] សុភក្តី ហៅ ធូ ភេទប្រុស អាយុ ២៣ឆ្នាំ,[redacted] ផានិត ហៅ ក្និត ភេទប្រុស អាយុ ២៣ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល ០៦ (ប្រាំមួយ)ឆ្នាំ ពីបទ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំងវាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងវាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌតាម មាត្រា ៣៥០ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៥-បង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ[redacted] ហេង ហៅ ស្រីហេង[redacted] សុភា ហៅ ភា,[redacted] ស្វិត ហៅ ស្វិត,[redacted]សុភក្តី ហៅ ធូ,[redacted] ផានិត ហៅ ក្និត តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៦-វត្ថុចាប់យកដូចមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១៥៣០ រ.វ.ត ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ ២០១៩ រួមមាន៖ ទូរស័ព្ទដៃចំនួនមួយគ្រឿងម៉ាក OPPO ពណ៌ទឹកមាស (មិនដំណើរការ) ។ ម៉ូតូមួយគ្រឿងម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១១ ពាក់ស្លាកលេខ ភ្នំពេញ 1BA-6484 (មិនប្រក្រតី) សម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ ។

៧-ពិរុទ្ធជនឈ្មោះ[redacted]វឌ្ឍា ឈ្មោះ[redacted]រះ ហៅ រះ ឈ្មោះ[redacted]សុវណ្ណ ហៅ ហ្គិច មានសិទ្ធិប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់ ។ ជនជាប់ចោទឈ្មោះ[redacted] ហេង ហៅ ស្រីហេង ឈ្មោះ[redacted] សុភា ហៅ ភា ឈ្មោះ[redacted]លីហ៊ាង ហៅ ហ៊ាង ឈ្មោះ[redacted]ស្វិត ហៅស្វិត ឈ្មោះ[redacted]សុភក្តី ហៅ ធូ ឈ្មោះ[redacted]ផានិត ហៅ ក្និត និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ស៊ីណាត មានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់ ។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ ប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ឈ្មោះ យូ រះ ហៅ រះ ឈ្មោះ [redacted] សុវណ្ណ ហៅ ហ្គិច កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហេង ហៅ ស្រីហេង ឈ្មោ[redacted] សុភា ហៅ ភា ឈ្មោ[redacted] លីហ៊ាង ហៅ ហ៊ាង ឈ្មោះ [redacted] ស្វិត ហៅ ស្វិត ឈ្មោះ [redacted] សុភក្តិ ហៅ ធូ ឈ្មោ[redacted] ផានិត ហៅ ក្និត និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីណាត ។

-បានឃើញៈ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ១១៧៧ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ ២២ឆ្នាំ ស៊ុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ១២៧៩ "ច១" ក្រ១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញៈ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខៈ ១១៨២ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ឈ្មោះ [redacted]ៈ ភេទប្រុស អាយុ ២៩ឆ្នាំ ស៊ុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ១២៧៩ "ច១" ក្រ១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញៈ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខៈ ១១៧៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ ១៨ឆ្នាំ ស៊ុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ១២៧៩ "ច១" ក្រ១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញៈ របាយការណ៍សំណុំរឿងព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ។

-បានឃើញៈ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១។

## នាពេលសវនាការ

| | | |
|---|---|---|
| -ជនជាប់ចោទឈ្មោះ | [redacted] រដ្ឋា | (វត្តមាន) |
| -ជនជាប់ចោទឈ្មោះ | [redacted] រះ | (វត្តមាន) |
| -ជនជាប់ចោទឈ្មោះ | [redacted] សុវណ្ណ | (វត្តមាន) |
| -មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ | [redacted] សុវណ្ណដារ៉ា | (វត្តមាន) |
| -មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ | [redacted] ច័ន្ទសុវណ្ណដា | (វត្តមាន) |
| -ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ | [redacted] ស៊ីណាត | (អវត្តមាន) |

-ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា បានឆ្លើយនាពេលសវនាការថា៖ ខ្លួនប្តឹងឧទ្ធរណ៍ព្រោះទោសធ្ងន់ពេក ខ្លួនទទួលស្គាល់ថាបានចូលរួមប្រព្រឹត្តមែន ។ នៅពេលប្រព្រឹត្ត ខ្លួនឃើញឈ្មោះ [redacted]ៈ ជិះម៉ូតូជាមួយគេ ចំពោះឈ្មោះ [redacted] សុវណ្ណ ខ្លួនមិនច្បាស់ថាបានចូលរួម ឬអត់ទេ ព្រោះមនុស្សច្រើន ។ ខ្លួនស្គាល់តែឈ្មោះ [redacted]ៈ ចំពោះឈ្មោះ [redacted] សុវណ្ណ ខ្លួនគ្រាន់តែស្គាល់គ្នាក្នុងភូមិ ហើយចំពោះកាំបិតវិញជារបស់ឈ្មោះ ភា ។ ពេលជួបជុំគ្នានោះ មានគ្នាច្រើននាក់ ប្រហែល១៤នាក់ ។ ដោយអ្នកចូលរួមច្រើន តែខ្លួនស្គាល់តែឈ្មោះ ភា និងឈ្មោះ [redacted]ៈ ចំណែកឈ្មោះ

[redacted]សុវណ្ណ គ្រាន់តែចំណាំមុខ ។ ពេលពួកខ្លួនចេញពីក្លឹប បានជួបជុំគ្នានៅទំនប់កប់ស្រូវ ។ ខ្លួនមិនបានប្រើប្រាស់គ្រឿងញៀនទេ ពេលធ្វើសកម្មភាពខ្លួនគ្រាន់តែជិះតាមគេ ។ ចំពោះឈ្មោះ ហ៊ួច ខ្លួនធ្លាប់តែបានលឺឈ្មោះក្នុងភូមិ ឈ្មោះ [redacted]សុវណ្ណ ក៏ដូចគ្នា តែមិនធ្លាប់ដើរលេងជាមួយគ្នាទេ ។ ខ្លួនសុំតុលាការបន្ធូរបន្ថយទោស ៦ខែ ។

-ជនជាប់ចោទឈ្មោ[redacted]រៈ បានឆ្លើយនាពេលសវនាការថា៖ ខ្លួនប្តឹងឧទ្ធរណ៍ព្រោះចង់សុំបន្ធូរបន្ថយទោស ។ នៅថ្ងៃកើតហេតុខ្លួនជិះជាមួយប្អូនក្នុងភូមិ ដោយវាត្រូវគេចាប់ខ្លួនដែរ ប៉ុន្តែមិនចោទប្រកាន់ទេ ។ ចំពោះលុយលក់ម៉ូតូ ខ្លួនមិនបានទទួលទេ ។ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀន ប៉ុន្តែពេលនេះខ្លួនឈប់ប្រើប្រាស់គ្រឿងញៀនហើយ ។ ខ្លួនមិនស្គាល់ឈ្មោះ[redacted]សុវណ្ណ ទេ ។

-ជនជាប់ចោទឈ្មោ[redacted] សុវណ្ណ បានឆ្លើយនាពេលសវនាការថា៖ ខ្លួនប្តឹងឧទ្ធរណ៍ព្រោះមិនបានធ្វើអ្វីខុស ខ្លួននៅផ្ទះសុខៗ សមត្ថកិច្ចក៏មកចាប់តែម្តង ។ ថ្ងៃកើតហេតុខ្លួននៅផ្ទះជាមួយម៉ាក់ប៉ា ចំពោះឈ្មោះ[redacted]ប៊ាង ឈ្មោះ ភក្ត្រាឈ្មោះ [redacted] សុភក្ត្រ ខ្លួនមិនដែលស្គាល់ទេ តែខ្លួនធ្លាប់ឃើញឈ្មោះទាំងនេះមកលាងម៉ូតូនៅកន្លែងខ្លួន ព្រោះខ្លួនបើកកន្លែងលាងម៉ូតូ ។ ខ្លួនត្រូវបានឃាត់ខ្លួននៅឆ្នាំ២០១៩ ដោយសមត្ថកិច្ចបានពិនិត្យទឹកនោម ប៉ុន្តែអត់មានសារធាតុញៀននោះទេ ។ ចំពោះឈ្មោះ[redacted]វឌ្ឍា និងឈ្មោ[redacted]រៈ ខ្លួនធ្លាប់ឃើញ ព្រោះធ្លាប់មកលាងម៉ូតូនៅកន្លែងខ្លួន ។ នៅពេលទៅដល់ខណ្ឌគេសួរថា ហ្វេងមានបក្សពួកអត់ គេវាយខ្លួន ហើយក៏បញ្ជូនខ្លួនមកព្រៃស ។ នៅតុលាការ ខ្លួនធ្លាប់បានឆ្លើយថាអត់ស្គាល់ឈ្មោ[redacted]រៈ និងឈ្មោះ[redacted]វឌ្ឍា ទេ ។

**តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា**

តាមការពិនិត្យសំណុំរឿង ឃើញថាជនជាប់ចោទឈ្មោះ[redacted] រៈ និងឈ្មោះ [redacted] វឌ្ឍា ឆ្លើយសារភាពទទួលកំហុសថាបានចូលរួម យកកាំបិតប្លន់យកម៉ូតូប្រាកដមែន ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ឆ្លើយបដិសេធថាពុំបានចូលរួមប្រព្រឹត្តទេ ។ ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ត្រូវបានចាប់ខ្លួន និងឃុំខ្លួនតាមអំណាចសាលក្រម ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ជនជាប់ចោទ ពុំបានបំពេញនីតិវិធីស៊ើបសួរដោយចៅក្រមស៊ើបសួរសួរទេ ។ ជនជាប់ចោទឈ្មោះ [redacted]សុវណ្ណ ពុំមានចម្លើយឆ្លើយដាក់បន្ទុកពីគូកនរបស់ជនជាប់ចោទទេ គឺមានតែរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ។ ត្រឹមតែជារបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវចាត់ទុកជាវិមតិសង្ស័យ ត្រង់ចំណុចនេះតំណាងមហាអយ្យការស្នើសុំឱ្យក្រុមប្រឹក្សាពិចារណា ។ ចំពោះជនជាប់ចោទឈ្មោះ [redacted]រៈ និងឈ្មោះ[redacted]វឌ្ឍា តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាបន្ធូរបន្ថយទោសខ្លះដល់ជនជាប់ចោទ ។

-លោក[redacted] សុវណ្ណដារ៉ា មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] សុវណ្ណ បានធ្វើសេចក្តីសន្និដ្ឋានថា ខ្លួនឯកភាពតាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។ ការចាប់កូនក្តីខ្លួន ផ្អែកតែលើចម្លើយរបស់ឈ្មោះ ហ៊ួច ដោយឈ្មោះ ហ៊ួច នេះមិនដឹងជាអ្នកណាមួយទេ ។ ក្នុងពេលសវនាការពេលនេះ ឈ្មោះ[redacted]វឌ្ឍា និងឈ្មោះ[redacted]រៈ បញ្ជាក់ហើយថា មិនស្គាល់កូនក្តីខ្លួនឈ្មោះ [redacted]សុវណ្ណ ទេ ។ ក្នុងរឿងនេះមានវិមតិសង្ស័យ ខ្លួនសុំក្រុមប្រឹក្សាសម្រេច

ឱ្យកូនក្តីខ្លួនឈ្មោះ [redacted]សុវណ្ណ រួចផុតពីបទចោទប្រកាន់ ។

-លោក [redacted]ព័ន្ធសុវណ្ណដា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សុវណ្ណ ជនជាប់ចោទឈ្មោះ [redacted]រដ្ឋា និងជនជាប់ចោទឈ្មោះ [redacted]រះ បានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីខ្លួនឈ្មោះ [redacted]រដ្ឋា និងឈ្មោះ[redacted]រះ ឆ្លើយសារភាព ថាបានចូលរួមប្រព្រឹត្ត ប៉ុន្តែពួកគាត់មិនមែនជាជនដៃដល់ទេ ម្យ៉ាងវិញទៀតជនរងគ្រោះក៏ពុំបានរងរបួសអ្វីដែរ។ ខ្លួនស្នើសុំក្រុមប្រឹក្សាបន្ធូរបន្ថយទោសដល់ជនជាប់ចោទឈ្មោះ[redacted]រះ និងឈ្មោះ[redacted]រដ្ឋា ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ គាត់បានឆ្លើយបញ្ជាក់ជូនក្រុមប្រឹក្សាហើយថា គាត់មិនបានចូលរួមប្រព្រឹត្តទេ ខ្លួនស្នើសុំក្រុមប្រឹក្សាសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted]សុវណ្ណ រួចផុតបទចោទប្រកាន់ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានពិនិត្យគ្រប់ឯកសារដែលពាក់ព័ន្ធ

-ក្រោយពីបានពិចារណាត្រឹមត្រូវហើយ

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍លេខ ១១៧៧ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បណ្តឹងឧទ្ធរណ៍លេខ: ១១៨២ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ[redacted]រះ និងបណ្តឹងឧទ្ធរណ៍លេខ: ១១៧៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted]រដ្ឋា ភេទប្រុស អាយុ ១៨ឆ្នាំ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ១២៧៩ "ច១" ក្រ១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ ផ្អែកតាមមាត្រា ៣៧៥ មាត្រា ៣៧៦ និងមាត្រា ៣៨២ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានជាសមត្ថកិច្ច ។

២-ជនជាប់ចោទឈ្មោ[redacted] រដ្ឋា បានឆ្លើយនាពេលសវនាការថា៖ ខ្លួនប្តឹងឧទ្ធរណ៍ព្រោះទោសធ្ងន់ពេក ខ្លួនទទួលស្គាល់ថាបានចូលរួមប្រព្រឹត្តមែន ។ នៅពេលប្រព្រឹត្ត ខ្លួនឃើញឈ្មោះ [redacted]រះ ជិះម៉ូតូជាមួយគេ ចំពោះឈ្មោះ [redacted] សុវណ្ណ ខ្លួនមិនច្បាស់ថាបានចូលរួម ឬអត់ទេ ព្រោះមនុស្សច្រើន ។ ខ្លួនស្គាល់តែឈ្មោះ [redacted] រះ ចំពោះឈ្មោះ [redacted]សុវណ្ណ ខ្លួនគ្រាន់តែស្គាល់គ្នាក្នុងភូមិ ហើយចំពោះកាំបិតវិញជារបស់ឈ្មោះ ភា ។ ពេលជួបជុំគ្នានោះ មានគ្នាច្រើននាក់ ប្រហែល១៤នាក់ ។ ដោយអ្នកចូលរួមច្រើន តែខ្លួនស្គាល់តែឈ្មោះ ភា និងឈ្មោះ[redacted]រះ ចំណែកឈ្មោះ [redacted] សុវណ្ណ គ្រាន់តែចំណាំមុខ ។ ពេលពួកខ្លួនចេញពីក្លឹប បានជួបជុំគ្នានៅទំនប់កប់ស្រូវ ។ ខ្លួនមិនបានប្រើប្រាស់គ្រឿងញៀនទេ ពេលធ្វើសកម្មភាពខ្លួនគ្រាន់តែជិះតាមគេ ។ ចំពោះឈ្មោះ ហ្គិច ខ្លួនធ្លាប់តែបានលឺឈ្មោះក្នុងភូមិ



Scanned with CamScanner

ឈ្មោះ[redacted]សុវណ្ណ ក៏ដូចគ្នា តែមិនធ្លាប់ដើរលេងជាមួយគ្នាទេ ។ ខ្លួនសុំតុលាការបន្ធូរបន្ថយទោស ៦ខែ ។

៣-ជនជាប់ចោទឈ្មោ[redacted] រៈ បានឆ្លើយនាពេលសវនាការថា៖ ខ្លួនប្ដឹងឧទ្ធរណ៍ព្រោះចង់សុំបន្ធូរបន្ថយទោស ។ នៅថ្ងៃកើតហេតុខ្លួនជិះជាមួយប្អូនក្នុងភូមិ ដោយវាត្រូវគេចាប់ខ្លួនដែរ ប៉ុន្តែមិនចោទប្រកាន់ទេ ។ ចំពោះលុយលក់ម៉ូតូ ខ្លួនមិនបានទទួលទេ ។ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀន ប៉ុន្តែពេលនេះខ្លួនឈប់ប្រើប្រាស់គ្រឿងញៀនហើយ ។ ខ្លួនមិនស្គាល់ឈ្មោះ[redacted]សុវណ្ណ ទេ ។

៤-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បានឆ្លើយនាពេលសវនាការថា៖ ខ្លួនប្ដឹងឧទ្ធរណ៍ព្រោះមិនបានធ្វើអ្វីខុស ខ្លួននៅផ្ទះសុខៗ សមត្ថកិច្ចក៏មកចាប់តែម្ដង ។ ថ្ងៃកើតហេតុខ្លួននៅផ្ទះជាមួយម៉ាក់ប៉ា ចំពោះឈ្មោ[redacted]ហ៊ាង ឈ្មោះ ភក្ត្រាឈ្មោះ[redacted] សុភក្ត្រ ខ្លួនមិនដែលស្គាល់ទេ តែខ្លួនធ្លាប់ឃើញឈ្មោះទាំងនេះមកលាងម៉ូតូនៅកន្លែងខ្លួន ព្រោះខ្លួនបើកកន្លែងលាងម៉ូតូ ។ ខ្លួនត្រូវបានឃាត់ខ្លួននៅឆ្នាំ២០១៩ ដោយសមត្ថកិច្ចបានពិនិត្យទឹកនោម ប៉ុន្តែអត់មានសារធាតុញៀននោះទេ ។ ចំពោះឈ្មោ[redacted]វឌ្ឍា និងឈ្មោះ[redacted]រៈ ខ្លួនធ្លាប់ឃើញ ព្រោះធ្លាប់មកលាងម៉ូតូនៅកន្លែងខ្លួន ។ នៅពេលទៅដល់ខណ្ឌគេសួរថា ហ្វែងមានបក្សពួកអត់ គេវាយខ្លួន ហើយក៏បញ្ជូនខ្លួនមកព្រៃស ។ នៅតុលាការ ខ្លួនធ្លាប់បានឆ្លើយថាអត់ស្គាល់ឈ្មោះ [redacted]រៈ និងឈ្មោ[redacted]វឌ្ឍា ទេ ។

៥-តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ តាមការពិនិត្យសំណុំរឿង ឃើញថាជនជាប់ចោទឈ្មោះ[redacted]រៈ និងឈ្មោះ[redacted] វឌ្ឍា ឆ្លើយសារភាពទទួលកំហុសថាបានចូលរួម យកកាំបិតប្លន់យកម៉ូតូប្រាកដមែន ។ ចំណែកជនជាប់ចោទឈ្មោះ[redacted]សុវណ្ណ ឆ្លើយបដិសេធថាពុំបានចូលរួមប្រព្រឹត្តទេ ។ ជនជាប់ចោទឈ្មោះ[redacted] សុវណ្ណ ត្រូវបានចាប់ខ្លួន និងឃុំខ្លួនតាមអំណាចសាលក្រម ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទឧទ្រិដ្ឋ ជនជាប់ចោទ ពុំបានបំពេញនីតិវិធីស៊ើបសួរដោយចៅក្រមស៊ើបសួរសួរទេ ។ ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ពុំមានចម្លើយឆ្លើយដាក់បន្ទុកពីគូកនរបស់ជនជាប់ចោទទេ គឺមានតែរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ។ ត្រឹមតែជារបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវចាត់ទុកជាវិមតិសង្ស័យ ត្រង់ចំណុចនេះតំណាងមហាអយ្យការស្នើសុំឱ្យក្រុមប្រឹក្សាពិចារណា ។ ចំពោះជនជាប់ចោទឈ្មោ[redacted] រៈ និងឈ្មោះ [redacted]វឌ្ឍា តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាបន្ធូរបន្ថយទោសខ្លះដល់ជនជាប់ចោទ ។ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍នឹងពិចារណាចំពោះការលើកឡើងនេះ ។

៦-លោក [redacted] សុវណ្ណដារ៉ា មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បានធ្វើសេចក្ដីសន្និដ្ឋានថាខ្លួនឯកភាពតាមសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។ ការចាប់កូនក្ដីខ្លួន ផ្អែកតែលើចម្លើយរបស់ឈ្មោះ ហ្គិច ដោយឈ្មោះ ហ្គិច នេះមិនដឹងជាអ្នកណាមួយទេ ។ ក្នុងពេលសវនាការពេលនេះ ឈ្មោះ [redacted] វឌ្ឍា និងឈ្មោ[redacted]រៈ បញ្ជាក់ហើយថា មិនស្គាល់កូនក្ដីខ្លួនឈ្មោ[redacted]សុវណ្ណ ទេ ។ ក្នុងរឿងនេះមានវិមតិសង្ស័យ ខ្លួនសុំក្រុមប្រឹក្សាសម្រេចឱ្យកូនក្ដីខ្លួនឈ្មោះ[redacted] សុវណ្ណ រួចផុតពីបទចោទប្រកាន់ ។ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍នឹងពិចារណាចំពោះការលើកឡើងនេះ ។



Scanned with CamScanner

៧-លោក [redacted] ច័ន្ទសុវណ្ណដា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ជនជាប់ចោទឈ្មោះ [redacted] វដ្ឋា និងជនជាប់ចោទឈ្មោះ [redacted] រ: បានធ្វើសេចក្ដីសន្និដ្ឋានថា៖ កូនក្ដីខ្លួនឈ្មោះ [redacted] វដ្ឋា និងឈ្មោះ [redacted] រ: ឆ្លើយសារភាព ថាបានចូលរួមប្រព្រឹត្ត ប៉ុន្តែពួកគាត់មិនមែនជាជនដៃដល់ទេ ម្យ៉ាងវិញទៀតជនរងគ្រោះក៏ពុំបានរងរបួសអ្វីដែរ។ ខ្លួនស្នើសុំក្រុមប្រឹក្សាបន្ធូរបន្ថយទោសដល់ជនជាប់ចោទឈ្មោ [redacted] រ: និងឈ្មោះ [redacted] វដ្ឋា ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ គាត់បានឆ្លើយបញ្ជាក់ជូនក្រុមប្រឹក្សាហើយថា គាត់មិនបានចូលរួមប្រព្រឹត្តទេ ខ្លួនស្នើសុំក្រុមប្រឹក្សាសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ រួចផុតបទចោទប្រកាន់ ។ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍នឹងពិចារណាចំពោះការលើកឡើងនេះ ។

៨-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ហ្គិច បានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ប៉ុន្តែតាមការពិនិត្យរបាយការណ៍សំយោគ លេខ ០៨៥/១៩ របក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ ឃើញថាជនជាប់ចោទឈ្មោះ [redacted] វដ្ឋា និងជនជាប់ចោទឈ្មោះ [redacted]: បានឆ្លើយបញ្ជាក់ថា កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ ឈ្មោះ ហ្គិច បើកម៉ូតូម៉ាកសេ ១២៥ ឌុបឈ្មោះ ស្វិត ។ ចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ហ្គិច ពុំមានភស្តុតាងតាមផ្លូវច្បាប់សម្រាប់ឱ្យសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ពិចារណាបានទេ ។

៩-សកម្មភាពរបស់ជនជាប់ចោទជាទម្រង់មួយនៃអំពើដែលមានធាតុផ្សំនៃបទល្មើស និងភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលច្បាប់បានចែង និងតម្រូវឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដូចមានចែងក្នុងសំអាងហេតុនៃសាលក្រមព្រហ្មទណ្ឌ លេខ ១២៧៩ “ច១” ក្រ១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បានឯកភាព ហេតុនេះសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍មិនលើកយកសំអាងហេតុដដែលនេះមកធ្វើការបញ្ជាក់ជាថ្មីទៀតទេ ។

១០-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] វដ្ឋា ហៅ ថា ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ ឈ្មោ [redacted]: ហៅ រ: ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] សុវណ្ណ ហៅ ហ្គិច ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាត្រពាំងវាំង ផ្លូវវិមានឈ្នះ១ ភូមិត្រពាំងវាំង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

១១-សាលក្រមព្រហ្មទណ្ឌលេខ ១២៧៩ “ច១” ក្រ១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្ដីមកនេះត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ហើយ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍



Scanned with CamScanner

គប្បីតម្កល់សាលក្រមព្រហ្មទណ្ឌនេះ ទុកជាបានការដដែល ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ ១១៧៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] រដ្ឋា និងបណ្ដឹងឧទ្ធរណ៍លេខ ១១៧៧ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] សុវណ្ណ និងបណ្ដឹងឧទ្ធរណ៍លេខ ១១៨២ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ឈ្មោះ[redacted]ះ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១២៧៩ “ច១” ក្រ១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៣-បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

សាលដីកានេះបានជំនុំជំរះកាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ឈ្មោះ [redacted]ះ និងឈ្មោះ [redacted]សុវណ្ណ ហៅ ហ្គិច កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]ស៊ីណាត និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ។

ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

---

“បានចម្លងត្រឹមត្រូវតាមច្បាប់ដើម”

ថ្ងៃព្រហស្បតិ៍ ៦កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

សាលាឧទ្ធរណ៍ភ្នំពេញ, ថ្ងៃទី ៩ ខែ ១២ ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]